

# ខគ្គវិសាណសូត្រ

## ៤១ ព្រះគាថា


រៀបរៀងដោយ

ភិក្ខុមេត្តាធនោ មឿន សឺន


(សម្រាប់ជាធម្មទាន)


ពុទ្ធសករាជ ២៥៦៧

# ខគ្គវិសាណសូត្រ

# ៤១ ព្រះគាថា

ការផ្សាយរបស់វត្តព្រះគន្ធកុដិ

រៀបរៀងដោយ

ភិក្ខុមេត្តាធនោ មឿន សឺន

(សម្រាប់ជាធម្មទាន)

ពុទ្ធសករាជ ២៥៦៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រវត្តិរូបសង្ខេប

-គោត្តនាម-នាម : **មឿន សឺន** ជាអក្សរឡាតាំង **MOEUN SEUN** នាមបញ្ញត្តិ **មេត្តាធនោ** ភេទ បព្វជិត បួសបាន១៥ វស្សា អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឆាយាលេខ ០៣៧៤៧០

-ថ្ងៃខែឆ្នាំកំណើត : ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំវក ចត្វាស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃទី ០១ ខែតុលា ឆ្នាំ១៩៩២

-ទីកន្លែងកំណើត : ភូមិផ្លូវលាវ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

-ថ្ងៃ-ខែ-ឆ្នាំបព្វជ្ជា : ថ្ងៃព្រហស្បតិ៍ ០៦រោច ខែអស្សុជ ឆ្នាំកុរ នព្វស័ក ព.ស.២៥៥១
ត្រូវនឹងថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០០៧

-ទីកន្លែងបព្វជ្ជា : **វត្តពោធិរុក្ខារាម (ដុងអារញ្ញ)** សង្កាត់និមន្ត ក្រុងប៉ោងប៉ែត ខេត្តបន្ទាយមានជ័យ

-នាមព្រះឧបជ្ឈាយ៍ : **គុណាទិនយោ ណាន់ សុចិន្តា** តួនាទី អនុគណស្រុកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

-ថ្ងៃ-ខែ-ឆ្នាំឧបសម្បទា : ថ្ងៃពុធ ១៤កើត ខែទុតិយាសាឍ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦
ត្រូវនឹងថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២

-ទីកន្លែងឧបសម្បទា : **វត្តគិរីបទរិការាម (ភ្នំតាមាឃ)** ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

-នាមព្រះឧបជ្ឈាយ៍ : **ខន្តិកោ ហាម ឈឿន** តួនាទី ព្រះគ្រូវជិរប្បញ្ញោ អនុគណស្រុករតនមណ្ឌល ខេត្តបាត់ដំបង វត្តគិរីបទរិការាម (ភ្នំតាមាឃ) ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

-នាមឧបសម្បទាចារ្យ : **ជោតិធម្មោ ឆុង ម៉េត**

-នាមអនុស្សាវនាចារ្យ : **ជិរសីលោ ឈឿន សាន**

-ឪពុកឈ្មោះ : **មឿន មុន** ឆ្នាំ១៩៦២ មុខរបរ កសិករ
ភូមិផ្លូវលាវ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

-ម្តាយឈ្មោះ : **ផន ស៊ីម** ឆ្នាំ១៩៦២ មុខរបរ កសិករ
ភូមិផ្លូវលាវ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

-បងប្អូនបង្កើត : ចំនួន០៥ នាក់ ប្រុស ០១ ស្រី ០៤

-កម្រិតវប្បធម៌ : ពុទ្ធចក្រ ធម្មវិន័យ ថ្នាក់ **ត្រី ទោ ឯក** **ព្រះវិន័យបិដក**
អាណាចក្រ **បរិញ្ញាបត្រ** ជំនាញពត៌មានវិទ្យា **(NUBB)**

ជំនាញ និងភាសា : **កុំព្យូទ័រ,**

ឋានៈនិងតួនាទី : **លោកគ្រូសូត្រស្តាំវត្តព្រះគន្ធកុដិ ជំនួយការសាលាគណខេត្តបាត់ដំបង ទទួលបន្ទុកបច្ចេកទេសរដ្ឋបាល នៃប្រព័ន្ធបច្ចេកវិទ្យា និងវិន័យាចារ្យ**

-លេខទូរសព្ទ 096 980 6368, Facebook,moeun seun -gmail,manmha2562@gmail.com

-អាសយដ្ឋានបច្ចុប្បន្ន **វត្តព្រះគន្ធកុដិ(គន្ធកុដិ)** សង្កាត់រតនៈ ក្រុងបាត់ដំបង់ ខេត្តបាត់ដំបង

ថ្ងៃអាទិត្យ ៨រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣
**ភិក្ខុ មេត្តាធនោ មឿន សឺន**

# តីណិសរណាគមនិយត្ថេរាបទាន

(បិដក.៧២. ទំព័រ.១៧១-១៧២)

ពុទ្ធោ លោកេ សមុប្បន្នោ   វត្តតេ ជិនសាសនំ
អមតា វេទិតា ភេរិ   សោកសល្លវិនោទនា ។

ព្រះសម្ពុទ្ធត្រាស់ដឹងហើយក្នុងលោក សាសនាព្រះជិនស្រីកំពុងផ្សាយទៅ ស្គរគឺអមតនិព្វានជាគ្រឿងបន្ទោបង់នូវសរ គឺសោកព្រះអង្គទូងហើយ ។

យថាសកេន ថាមេន   បុញ្ញក្ខេត្តេ អនុត្តរេ
អធិការំ ករេយ្យាថ   បស្សយិស្សថ និព្វុតឹ ។

អ្នកទាំងឡាយគប្បីធ្វើនូវការកសាង ក្នុងបុញ្ញក្ខេត្តដ៏ប្រសើរគួរតាមកម្លាំងរបស់ខ្លួនចុះ អ្នកទាំងឡាយនឹងឃើញ នូវការរំលត់ទុក្ខ ។

បគ្គយ្ហ តីណិ សរណេ   បញ្ចសីលានិ គោបិយ
ពុទ្ធេ ចិត្តំ បសាទេត្វា   ទុក្ខស្សន្តំ ករិស្សថ ។

អ្នកទាំងឡាយគួរទទួលត្រៃសរណគមន៍ រក្សាសីល ៥ ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ នឹងធ្វើនូវទីបំផុតទុក្ខបាន ។

# អារម្ភកថា

សៀវភៅ **ខគ្គវិសាណសូត្រ** នេះកើតឡើងដោយអាស្រ័យហេតុដែលខ្ញុំព្រះករុណាអាត្មាភាព បានសិក្សារៀនសូត្រព្រះធម៌ព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ តាមរយៈព្រះត្រៃបិដក មួយអន្លើដោយព្រះអដ្ឋកថា បានឃើញព្រះពុទ្ធដីកាពីរោះៗ ដែលសមគួរដល់ការសិក្សារបស់ព្រះសង្ឃ និងពុទ្ធបរិស័ទក្នុងសាសនព្រហ្មចរិយនេះ ព្រោះហេតុនោះ បានជាខ្ញុំព្រះករុណាអាត្មាភាព ខំប្រឹងសិក្សាស្រាវជ្រាវ ដកស្រង់ព្រះពុទ្ធដីកាអដ្ឋកថាក្នុង សុត្តន្តបិដក ខុទ្ទកនិកាយ ខគ្គវិសាណសូត្រ ដែលជាឧទានរបស់ព្រះបច្ចេកពុទ្ធ ប្រកបដោយអត្ថរស និងធម្មរស ព្រមទាំងសេចក្តីស្ងប់ស្ងាត់ ជាបុគ្គលម្នាក់ឯងប្រព្រឹត្តទៅដើម្បីព្រះនិព្វានតែម៉្យាង ។ ខ្ញុំព្រះករុណាបាននាំយក ព្រះសូត្រនេះមក សរសេរជាសៀវភៅនេះឡើង ដើម្បីជាប្រយោជន៍សម្រាប់ពុទ្ធបរិស័ទសិក្សារៀនសូត្រ និងគោរពប្រតិបត្តិ ដើម្បីសេចក្តីចម្រើនក្នុង ព្រះពុទ្ធសាសនាតទៅ ។

ខ្ញុំព្រះករុណាសូមខន្តីអភ័យទោស ចំពោះកំហុសខុសឆ្គងត្រង់ចំណុចខ្វះខាត ដែលកើតឡើងដោយអចេតនា ក្នុងការសរសេរសៀវភៅនេះឡើង សូមលោកម្ចាស់ និងញាតិញោម អត់នូវទោសនោះដល់ខ្ញុំព្រះករុណាផងចុះ ។

**សូមអនុមោទនា !!!**

## បណាមគាថា

ខ្ញុំសូមនមស្ការព្រះសម្ពុទ្ធដ៏ឧត្តម មិនមានបុគ្គលប្រៀបស្មើឡើយ ទ្រង់ឡើងអំពីសាគរនៃញេយ្យធម៌ទ្រង់ឆ្លងសង្សារសាគរបានហើយ ដោយសិរសាគឺត្បូង ព្រមទាំងព្រះធម៌ដ៏ជ្រាលជ្រៅ ជាធម៌ស្ងប់ល្អិតសុខុម លំបាកនឹងឃើញបាន ជាធម៌ទម្លាយនូវភពតូច និងភពធំ ដែលបុគ្គលគួរបូជាមួយអន្លើដោយព្រះសង្ឃដែលប្រាសចាកកិលេស ឧត្តមជាងមហាជន ជាអគ្គទក្ខិណេយ្យបុគ្គល មានឥន្ទ្រិយស្ងប់ហើយមិនមានអាសវៈដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ ។

ដោយបណាមគាថានេះ ដែលខ្ញុំធ្វើហើយចំពោះ ព្រះរតនត្រ័យដោយការពោលសរសើរដោយវិសេសនេះ ខ្ញុំនឹងពណ៌នាអត្ថដ៏វិចិត្រនៃព្រះបាលី ក្នុងព្រះត្រៃបិដកមួយអន្លើដោយអដ្ឋកថាដែលធ្វើឱ្យអ្នករៀន និងអ្នកទ្រទ្រង់ចាំបានដោយងាយ ព្រោះដូច្នោះរមែងឱ្យសម្រេចប្រយោជន៍តាមដែល សាធុជនត្រូវការ ព្រោះហេតុនោះ ខ្ញុំនឹងអាស្រ័យន័យរបស់ព្រះពុទ្ធដីកា និងអដ្ឋកថាតាមលំនាំដើម របស់ព្រះមហាថេរៈទាំងឡាយ ជាអ្នកពោលពាក្យមិនដែលខុសភ្លាំងភ្លាត់ សម្ដែងតែអត្ថដែលត្រឹមត្រូវធ្វើការពណ៌នា ចំពោះបទដែលប្លែកដែលល្អបំផុតប៉ុណ្ណោះដោយប្រការដូច្នេះ។

ជាទីបញ្ចប់ដោយផលនៃការខំប្រឹងប្រែងរបស់ខ្ញុំព្រះករុណាសូមលើកឡើងនូវមហាកុសលថ្នាក់ធម្មទាននេះ និងបុណ្យកុសលគ្រប់បែបយ៉ាង ដែលបានសន្សំហើយក្នុងព្រះពុទ្ធសាសនានេះ ជាពិសេសបុណ្យ

កុសលដែលបាន បំពេញសម្រេចនៅលើទឹកដីពុទ្ធភូមិមាន ប្រទេសឥណ្ឌា ប្រទេសណេប៉ាល់ ប្រទេសស្រីលង្កា និងប្រទេសភូមា ខ្ញុំព្រះករុណាសូមប្រគេនបុណ្យទាំងអស់នោះចំពោះ ៖

លោកគ្រូ **មហាសទ្ធម្មធរជោតិក ហ៊ី ធីតៅ**

លោកគ្រូ **វិនយាចារ្យ កល្យាណធម្មោ យឿន កល្យាណ**

លោកគ្រូ **វិនយាចារ្យ ញាតិធម្មោ ពុយ សុវត្ថិឌី** និងលោកគ្រូ **ជ័យ សុហុន**

លោកគ្រូ **អគ្គបណ្ឌិត ប៊ុត សាវង្ស**

មួយចំណែកទៀតសូមជូនចំពោះ ញោមប្រុស មឿន មុន និងញោមស្រី ជន ស៊ឹម ដែលមានជីវិតរស់នៅសព្វថ្ងៃនេះដែលជាលោកអ្នកមាននូវគុណដ៏ធំក្រៃលែងចំពោះខ្ញុំព្រះករុណា ។

ឧទ្ទិសប្រគេន និងជូនបុណ្យចំពោះលោកគ្រូ **កិត្តិបណ្ឌិតភាសាបាលី ប្រាក់ យុន លោកគ្រូអគ្គបណ្ឌិតោ យង់ សុផាត លោកគ្រូវិនយាចារ្យ តាំ អ៊ីវ** ជូនចំពោះលោកអ្នកមានគុណទាំងអស់ក្នុងសង្សារវដ្ត និងសព្វសត្វទាំងអស់ក្នុងត្រៃភព សូមបានចំណែកបុណ្យស្មើៗគ្នា កុំបីទៅជាបការៈដទៃឡើយ ។

**សូមអនុមោទនា**.........!!!

**វត្តព្រះគន្ធកុដិ** ថ្ងៃអាទិត្យ ៨រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣

**ភិក្ខុ មេត្តាធនោ មឿន សឺន**

## មាតិកាធម៌ ទំព័រ


គីណាិសរណាកមិនិយក្ដោបទាន ក
បណាមកាថា ខ
អារម្ភកថា គ
[១]បឋមកាថាទី១ ១
[២]សំសក្កកាថាទី២ ២
[៣]មិត្តសុហជ្ជេកាថាទី ៣ ៣
[៤] ទំសកឡ៊ីរកាថាទី ៤ ៤
[៥] មិគអរញ្ញកាថាទី ៥ ៥
[៦] អានន្ទកាថាទី ៦ ៦
[៧] ខិឌ្ឌារតិកាថាទី ៧ ៧
[៨] ចាតុទ្ទិសកាថាទី ៨ ៨
[៩] ទុស្សង្គហកាថាទី ៩ ៩
[១០] កោទិឡ្ឋារកាថាទី ១០ ១០
[១១] សហាយកាថាទី ១១ ១១
[១២] សហាយកាថាទី ១២ ១២
[១៣] ទដ្ឋភោជិកាថាទី ១៣ ១៣
[១៤] សុទណ្ណកាថាទី ១៤ ១៤
[១៥] អាយតិភយកាថាទី ១៥ ១៥
[១៦] កាមកាថាទី ១៦ ១៦
[១៧] ឦតិកាថាទី ១៧ ១៧

[១៨] សីគាលុកកាថាទី ១៨ ១៨
[១៩] នាគកាថាទី ១៩ ១៩
[២០] អដ្ឋានកាថាទី ២០ ២០
[២១] ទិដ្ឋីវិសូកកាថាទី ២១ ២១
[២២] និល្លោលុបកាថាទី ២២ ២២
[២៣] ចាបសហាយកាថាទី ២៣ ២៣
[២៤] ពហុស្សុតកាថាទី ២៤ ២៤
[២៥] វិភូសកដ្ឋានកាថាទី ២៥ ២៥
[២៦] បុត្តទារកាថាទី ២៦ ២៦
[២៧] សទ្ធកាថាទី ២៧ ២៧
[២៨] សន្ទាលនកាថាទី ២៨ ២៨
[២៩] ឱក្ខិត្តចក្ខុកាថាទី ២៩ ២៩
[៣០] ចារិច្ឆត្តព្រឹក្សកាថាទី ៣០ ៣០
[៣១] រសកេដកាថាទី ៣១ ៣១
[៣២] អាទណកាថាទី ៣២ ៣២
[៣៣] វិបិដ្ឋីកគ្វានកាថាទី ៣៣ ៣៣
[៣៤] អារទ្ធវិរិយកាថាទី ៣៤ ៣៤
[៣៥] បដិសល្លានកាថាទី ៣៥ ៣៥
[៣៦] គណ្ហាក្ខយកាថាទី ៣៦ ៣៦
[៣៧] អសន្តសន្តកាថាទី ៣៧ ៣៧
[៣៨] ទាឋពលិកាថាទី ៣៨ ៣៨
[៣៩] អប្បមញ្ញាកាថាទី ៣៩ ៣៩

[៤០] ជីវិតសង្ខយកាថាទី ៤០ ៤០
[៤១] ការណត្ថុកាថាទី ៤១ ៤១

# ខគ្គវិសាណសូត្រ

## [១] បឋមគាថាទី ១

(បិដក.៥៤.ទំព័រ.១២)

**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**
**អវិហេឋយំ អញ្ញតរម្បិ តេសំ**
**ន បុត្តមិច្ឆេយ្យ កុតោ សហាយំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល ដាក់អាជ្ញាចោលចេញ ចំពោះពួកសត្វទាំងអស់ មិនបៀតបៀន នូវសត្វទាំងនោះ សូម្បីសត្វណាមួយ មិនគប្បីប្រាថ្នានូវបុត្រ តើគប្បីត្រូវការសម្លាញ់ អំពីណា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២] សំសគ្គគាថាទី ២

(បិដក.៥៤.ទំព័រ.១២)

**សំសគ្គជាតស្ស ភវន្តិ ស្នេហា**
**ស្នេហាន្វយំ ទុក្ខមិទំ បហោតិ**
**អាទីនវំ ស្នេហជំ បេក្ខមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

សេចក្តីស្រឡាញ់ រមែងមាន ដល់បុគ្គលដែល
ច្រឡូកច្រឡំ ទុក្ខដែលជាប់តាម ចំពោះសេចក្តី
ស្រឡាញ់នេះ ក៏រមែងកើតឡើង បុគ្គលឃើញ
ទោស ដែលកើតអំពីសេចក្តីស្រឡាញ់ហើយ
គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣] មិត្តសុហជ្ជគាថាទី ៣

(បិដក.៥៤.ទំព័រ.១២)

**មិត្តេ សុហជ្ជេ អនុកម្បមានោ**

**ហាបេតិ អត្ថំ បដិពទ្ធចិត្តោ**

**ឯតំ ភយំ សន្ថវេ បេក្ខមានោ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល អ្នកមានចិត្តប្រតិព័ទ្ធ កាលអនុគ្រោះ

នូវពួកមិត្ត ដែលមានចិត្តល្អ រមែងញុំាងប្រយោជន៍

ឲ្យសាបសូន្យ បុគ្គលកាលឃើញ នូវភ័យក្នុង

ការមូលមិត្តភ្ជាន់ភ្ជុំហើយ គប្បីត្រាច់ទៅតែ

ម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៨] វំសកឡីរគាថាទី ៨

(បិដក.៥៤.ទំព័រ.១៤)

**វំសោ វិសាលោ វ យថា វិសត្តោ**
**បុត្តេសុ ទារេសុ ច យា អបេក្ខា**
**វំសាកឡីរោវ អសជ្ជមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

សេចក្តីស្រឡាញ់ ចំពោះកូននិងប្រពន្ធ ដូចឫស្សី
ដែលបែកគុម្ព ចាកកណ្តាញ់ បុគ្គលកាលមិន
ជាប់ជំពាក់ ដូចជាទំពាំងឫស្សី គប្បីត្រាច់ទៅតែ
ម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៩] មិគអរញ្ញគាថាទី ៩

(បិដក.៥៤.ទំព័រ.៣៤)

**មិគោ អរញ្ញម្ហិ យថា អពន្ធោ**
**យេនិច្ឆកំ គច្ឆតិ គោចរាយ**
**វិញ្ញូ នរោ សេរិតំ បេក្ខមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ម្រឹកក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណី
តាមចំណង់ចិត្តបាន យ៉ាងណា វិញ្ញូជន កាល
បើឃើញ សេរីភាព ( យ៉ាងនោះ ) គប្បីត្រាច់
ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៦] អានន្ទគាថាទី ៦

(បិដក.៥៤.ទំព័រ.១៤)

**អាមន្តនា ហោតិ សហាយមជ្ឈេ**
**វាសេ ឋានេ គមនេ ចារិកាយ**
**អនភិជ្ឈិតំ សេវិតំ បេក្ខមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ការហៅរករមែងមាន ដល់ជនឋិតនៅ ក្នុងកណ្តាល នៃសម្លាញ់ គឺការនៅ ការឈរ និងការត្រាច់ចារិក បុគ្គលកាលឃើញ សេរីភាពដែល (ពួកជនពាល ) មិនប្រាថ្នា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

**[៧] ខិឌ្ឍារតិគាថាទី ៧**

(បិដក.៥៤.ទំព័រ.១៥)

**ខិឌ្ឍា រតី ហោតិ សហាយមជ្ឈេ**

**បុត្តេសុ ច វិបុលំ ហោតិ បេមំ**

**បិយវិប្បយោគំ វិជិគុច្ឆមានោ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ការលេង ការត្រេកអរ ក្នុង (កាមគុណ )

រមែងមាន ដល់ជនឋិតនៅ ក្នុងកណ្តាល នៃសម្លាញ់

មួយទៀត សេចក្តីស្រឡាញ់ ដ៏ទូលាយ រមែង

មានក្នុងបុត្តទាំងឡាយ បុគ្គលកាលបើធុញទ្រាន់

នឹងការព្រាត់ប្រាស ចាកសត្វនិងសង្ខារ ជាទី

ស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង

ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៨] ចាតុទ្ទិសគាថាទី ៨

(បិដក.៥៤.ទំព័រ.១៥)

**ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ**
**សន្តុស្សមានោ ឥតរីតរេន**
**បរិស្សយានំ សហិតា អឆម្ភី**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល ជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤
មិនលំបាក ត្រេកអរ ដោយបរិក្ខារ តាមមាន
តាមបាន ជាអ្នកអត់ធន់ ចំពោះអន្តរាយទាំងឡាយ
ទាំងជាអ្នកមិនតក់ស្លុត គប្បីត្រាច់ទៅតែម្នាក់ឯង
ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៩] ទុស្សង្គហគាថាទី ៩

(បិដក.៥៤.ទំព័រ.១៥)

**ទុស្សង្គហា បព្វជិតាបិ ឯកេ**

**អថោ គហដ្ឋា ឃរមាវសន្តា**

**អប្បោស្សុក្កោ បរបុត្តេសុ ហុត្វា**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បព្វជិតពួកខ្លះ ឬគ្រហស្ថអ្នកក្រប់ក្រងផ្ទះ គេ
សង្គ្រោះ បានដោយកម្រ បុគ្គលមិនមានសេចក្តី
ខ្វល់ខ្វាយ ចំពោះបុត្ត នៃបុគ្គលដទៃ គប្បីត្រាច់
ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១០] កោវិឡារគាថាទី ១០

(បិដក.៥៤.ទំព័រ.១៦)

**ឱរោបយិត្វា គិហិព្យញ្ជនានិ**

**សញ្ឆិន្នបត្តោ យថា កោវិឡារោ**

**ឆេត្វាន ធីរោ គិហិពន្ធនានិ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ដីរបុរស លះបង់ នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដ នូវភាពជាគ្រហស្ថ កាត់ចំណង របស់គ្រហស្ថទាំងឡាយ ដូចជារលួសផ្គុំ ជម្រុះស្លឹក គប្បីត្រាច់ទៅតែម្នាក់ឯង ។

# ខគ្គវិសាណសូត្រ

## [១១] សហាយគាថាទី ១១

(បិដក.៥៤.ទំព័រ.១៦)

**សចេ លភេថ និបកំ សហាយំ**

**សទ្ធឹចរំ សាធុវិហារិ ធីរំ**

**អភិភុយ្យ សព្វានិ បរិស្សយានិ**

**ចរេយ្យ តេនត្តមនោ សតីមា ។**

បើបុគ្គលបានប្រាជ្ញ មានជមីជាគ្រឿងនៅ

ដោយប្រពៃ ជាសម្លាញ់ មានប្រាជ្ញាខ្ជាប់

ខ្ជួន ត្រាច់ទៅ ជាមួយគ្នា គ្របសង្កត់នូវសេចក្តី

អន្តរាយទាំងពួងបាន គប្បីមានចិត្តត្រេកអរ មាន

ស្មារតី ត្រាច់ទៅជាមួយសម្លាញ់នោះទៅចុះ ។

# ខគ្គវិសាណសូត្រ

## [១២] សហាយគាថាទី ១២

(បិដក.៥៤.ទំព័រ.១៦)

**នោ ចេ លភេថ និបកំ សហាយំ**
**សទ្ធឹចរំ សាធុវិហារិ ធីរំ**
**រាជាវ រដ្ឋំ វិជិតំ បហាយ**
**ឯកោ ចរេ មាតង្គរញ្ញេវ នាគោ។**

បើបុគ្គល រកអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅ ដោយប្រពៃ ជាសម្លាញ់ មានប្រាជ្ញាខ្ជាប់ខ្ជួន ត្រាច់ទៅជាមួយគ្នា ពុំបានទេ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចព្រះរាជាលះបង់ នូវដែនដែលព្រះអង្គឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គៈ លះបង់ហ្វូង ត្រាច់ទៅក្នុងព្រៃ ។

# ខគ្គវិសាណសូត្រ

## [១៣] វជ្ជភោជីគាថាទី ១៣

(បិដក.៥៤.ទំព័រ.១៧)

**អទ្ធា បសំសាម សហាយសម្បទំ**
**សេដ្ឋា សមា សេវិតព្វា សហាយា**
**ឯតេ អលទ្ធា អនវជ្ជភោជី**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

តាមពិត យើងសរសើរ នូវការបរិបូណ៌ ដោយសម្លាញ់ហើយ តែសម្លាញ់ មានគុណប្រសើរជាង និងសម្លាញ់មានគុណស្មើ បុគ្គលគួរសេពគប់ រាប់រក បើ ( កុលបុត្រចង់បានប្រយោជន៍ ) រកសម្លាញ់ទាំងនុ៎ះ ពុំបានទេ គប្បីជាអ្នកបរិភោគភោជន ដែលមិនមានទោស ហើយត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១៤] សុវណ្ណគាថាទី ១៤

(បិដក.៥៤.ទំព័រ.១៧)

**ទិស្វា សុវណ្ណស្ស វលយានិ បភស្សរានិ**

**កម្មារបុត្តេន សុនិដ្ឋិតានិ**

**សង្ឃដ្ដមានានិ ទុវេ ភុជស្មឹ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលឃើញ ខ្នងកងមាសទាំងពីរ ដ៏ភ្លឺផ្លេក ដែល
ជាងមាស ជ្រើសម្រេចហើយ ដោយល្អ រណ្តំគ្នា
ឮដ៏ដៃ គប្បីត្រាច់ទៅ តែម្នាក់ឯងដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១៩] អាយតិភយគាថាទី ១៩

(បិដក.៥៤.ទំព័រ.១៧)

**ឯវំ ទុតិយេន សហា មមស្ស**

**វាចាភិលាបោ អភិសជ្ជនា វា**

**ឯតំ ភយំ អាយតិ បេក្ខមានោ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ការចរចា ដោយវាចាក្តី ការជាប់ចំពាក់ក្តី ជា

មួយនឹងកុមារ ជាកម្រប់ពីរ មានដល់អញយ៉ាងនេះ

បុគ្គលកាលបើឃើញ នូវភ័យនុ៎ះ តទៅខាងមុខហើយ

គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១៦] កាមគាថាទី ១៦

(បិដក.៥៤.ទំព័រ.១៧)

**កាមា ហិ ចិត្រា មធុរា មនោរមា**
**វិរូបរូបេន មថេន្តិ ចិត្តំ**
**អាទីនវំ កាមគុណេសុ ទិស្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ពិតណាស់ កាមទាំងឡាយ ដ៏វិចិត្រ មាន
រសផ្អែម ជាទីរីករាយនៃចិត្ត តែងញាំញី នូវចិត្ត
ដោយសភាព ដ៏ប្លែក ៗ បុគ្គលឃើញទោសក្នុង
កាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅ តែម្នាក់
ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១៧] ឈ្លតិគាថាទី ១៧

(បិដក.៥៤.ទំព័រ.១៨)

**ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច**
**រោគោ ច សល្លញ្ច ភយញ្ច មេតំ**
**ឯតំ ភយំ កាមគុណេសុ ទិស្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ចង្រៃ បូស ឧបទ្រព រោគ កិលេស
ដូចសរ និងភ័យទាំងនុ៎ះ រមែងមានដល់យើង (ព្រោះកាម ) បុគ្គលកាលបើឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង
ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១៨] សីតាលុកគាថាទី ១៨

(បិដក.៥៤.ទំព័រ.១៨)

**សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ**
**វាតាតបេ ឌំសសិរីំសបេ ច**
**សព្វានិបេតានិ អភិសម្ភវិត្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលគ្របសង្កត់ នូវសត្រូវ ទាំងអស់នុ៎ះ
គឺត្រជាក់ ក្តៅ កម្លាន សម្រេក ខ្យល់ និងកម្តៅថ្ងៃ
រហោម និងពស់ហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង
ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [១៧] នាគគាថាទី ១៧

(បិដក.៥៤.ទំព័រ.១៨)

**នាគោវ យូថានិ វិវជ្ជយិត្វា**

**សញ្ជាតខន្ធោ បទុមី ឧឡារោ**

**យថាភិរន្តំ វិហរំ អរញ្ញេ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ដំរី មានខ្លួនសមរម្យ មាំមួន មានសម្បុរ

ដូចផ្កាឈូក កាលលះបង់ ហ្វូងហ្វូង ហើយនៅក្នុង

ព្រៃ គួរដល់អធ្យាស្រ័យ យ៉ាងណា បុគ្គលគប្បីត្រាច់

ទៅ តែម្នាក់ឯង ដូចកុយរមាស (យ៉ាងនោះ ) ។

# ខគ្គវិសាណសូត្រ

## [២០] អដ្ឋានគាថាទី ២០

(បិដក.៥៤.ទំព័រ.១៩)

**អដ្ឋាន តំ សង្គណិការតស្ស**

**យំ ផុស្សយេ សាមយិកំ វិមុត្តឹ**

**អាទិច្ចពន្ធុស្ស វចោ និសម្ម**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលបាននូវវិមុត្តិ ប្រព្រឹត្តទៅ ក្នុងសម័យ

គឺលោកិយសមាបត្តិ ដោយហេតុណា ហេតុនោះ

មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរ ក្នុង

ពួកនេះ បុគ្គល ពិចារណាពាក្យ របស់ព្រះពុទ្ធ

ជាព្រះអាទិច្ចពន្ធុហើយ គប្បីត្រាច់ទៅ តែ

ម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២១] ទិដ្ឋីវិសូកគាថាទី ២១

(បិដក.៥៤.ទំព័រ.១៩)

**ទិដ្ឋីវិសូកានិ ឧបាតិវត្តោ**
**បត្តោ និយាមំ បដិលទ្ធមគ្គោ**
**ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលកន្លង នូវទិដ្ឋីអាក្រក់ ដល់នូវដំណឹងមានមគ្គបានហើយ មិនចាំបាច់មានអ្នកដទៃ ដឹកនាំ ព្រោះដឹងថា អាត្មាអញ មានញាណ កើតហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២២] និល្លោលុបគាថាទី ២២

(បិដក.៥៤.ទំព័រ.១៩)

**និល្លោលុបោ និក្កុហោ និប្បិបាសោ**
**និម្មក្ខោ និទ្ធន្តកសាវមោហោ**
**និរាសយោ សព្វលោកេ ភវិត្វា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលមិនជាប់ចិត្ត ក្នុងអាហារ មិនកុហក
មិនមានសេចក្ដីស្រេកឃ្លាន ជាអ្នកមិនលុបគុណគេ
កម្ចាត់បង់មោហៈ ដូចជាទឹកចត់ចេញបាន មិនមាន
ទីអាស្រ័យ (គឺកិលេស ) ក្នុងលោកទាំងមូល
គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២៣] ចាបសហាយគាថាទី ២៣

(បិដក.៥៤.ទំព័រ.១៩)

**ចាបំ សហាយំ បរិវជ្ជយេថ**

**អនត្ថទស្សឹ វិសមេ និវិដ្ឋំ**

**សយំ ន សេវេ បសុតំ បមត្តំ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលគប្បីវៀរ នូវសម្លាញ់ ដ៏អាក្រក់ ដែលបង្ហាញ នូវអំពើមិនជាប្រយោជន៍ អាស្រ័យនៅក្នុងកម្មមិនស្មើ (គឺទុច្ចរិត ) មិនគប្បីសេពគប់ នូវសម្លាញ់ ដែលជាប់ចំពាក់ ដែលស្រវឹង (ក្នុងកាមគុណ ) ដោយខ្លួនឯង គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២៨] ពហុស្សុតគាថាទី ២៨

(បិដក.៥៤.ទំព័រ.២០)

**ពហុស្សុតំ ធម្មធរំ ភជេថ**
**មិត្តំ ឧឡារំ បដិភាណវន្តំ**
**អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលគប្បីគប់រក នូវមិត្តជាពហុស្សុត ទ្រទ្រង់នូវធម៌ ប្រកបដោយគុណ ដ៏ថ្លៃថ្នូរ មានប្រាជ្ញាវាងវៃ លុះដឹងច្បាស់ នូវប្រយោជន៍ទាំងឡាយហើយ គប្បីបន្ទោបង់ នូវសេចក្តីសង្ស័យចេញ ត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២៩] ភិក្ខុសកដ្ឋានគាថាទី ២៩

(បិដក.៥៤.ទំព័រ.២០)

**ខិឌ្ឌំ រតឹ កាមសុខញ្ច លោកេ**

**អនលង្ករិត្វា អនបេក្ខមានោ**

**វិភូសនដ្ឋានា វិរតោ សច្ចវាទី**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល មិនគាក់តែង នូវការលេងផង ការ

ត្រេកអរផង កាមសុខផង ក្នុងលោក មិនអាឡោះ

អាល័យ វៀរចាកទីជាទីស្អិតស្អាង អ្នកពោល

ពាក្យពិត គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២៦] បុត្តទារគាថាទី ២៦

(បិដក.៥៤.ទំព័រ.២១)

**បុត្តញ្ច ទារំ បិតរញ្ច មាតរំ**

**ធនានិ ធញ្ញានិ ច ពន្ធវានិ**

**ហិត្វាន កាមានិ យថោធិកានិ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលលះបង់កូនផង ប្រពន្ធផង បិតាផង មាតាផង ទ្រព្យទាំងឡាយផង ស្រូវទាំងឡាយផង ពៅពង្សទាំងឡាយផង កាមទាំងឡាយ តាមចំណែករៀងខ្លួនផង គប្បីត្រាច់ផងទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

**[២៧] សង្គគាថាទី ២៧**

(បិដក.៥៤.ទំព័រ.២១)

**សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ**
**អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ**
**គណ្ឌោ ឯសោ ឥតិ ញត្វា មតិមា**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

កាមគុណនេះ ជាគ្រឿងជាប់ចំពាក់ សុខ
ក្នុងកាមគុណនេះ មានប្រមាណតិច កាមគុណ
មានសេចក្តីត្រេកអរតិច ទុក្ខក្នុងកាមគុណនេះច្រើន
ក្រៃលែង បុគ្គលអ្នកមានបញ្ញា ដឹងច្បាស់ថា
ការជាប់ចំពាក់ ក្នុងកាមគុណនុ៎ះ ដូចជាបូស
គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [២៨] សន្ទាលនគាថាទី ២៨

(បិដក.៥៤.ទំព័រ.២១)

**សន្ទាលយិត្វាន សំយោជនានិ**
**ជាលំ វ ភេត្វា សលិលម្ពុចារី**
**អគ្គីវ ទឌ្ឍំ អនិវត្តមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលទម្លាយ នូវសំយោជនៈ ដូចត្រី ក្នុងទឹក ទម្លាយបង់ នូវបណ្ដាញ មិនត្រឡប់មក ( រកសំយោជនៈ ) វិញ ដូចជាភ្លើងឆេះ (មិន ត្រឡប់វិលវិញ ) គប្បីត្រាច់ទៅ តែម្នាក់ឯង ដូច កុយរមាស ។

# ខគ្គវិសាណសូត្រ

## [២៧] ឱក្ខិត្តចក្ខុគាថាទី ២៧

(បិដក.៥៤.ទំព័រ.២២)

**ឱក្ខិត្តចក្ខុ ន ច បាទលោលោ**

**គុត្តិន្ទ្រិយោ រក្ខិតមានសានោ**

**អនវស្សុតោ អបរិឌយ្ហមានោ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលមានចក្ខុដាក់ចុះ មានជើង មិនរពឹស មានឥន្ទ្រិយគ្រប់គ្រងល្អ មានចិត្តរក្សាទុក មិនជោកជាំ មិនពេលពាល (ដោយកិលេស ) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣០] ថាវិច្ឆត្តព្រីក្សគាថាទី ៣០

(បិដក.៥៤.ទំព័រ.២២)

**ឱហារយិត្វា គិហិព្យញ្ជនានិ**

**សញ្ឆិន្នបត្តោ យថា បារិឆត្តោ**

**កាសាយវត្ថោ អភិនិក្ខមិត្វា**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលលះបង់ នូវវត្ថុជាគ្រឿងព្រាកដ នូវភាពជាគ្រហស្ថ ដូចដើមថារិច្ឆត្តព្រឹក្ស មានស្លឹកជម្រុះហើយ គប្បីជាអ្នកមានសំពត់កាសាយៈ ចេញបួស ត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣១] រសេគេធគាថាទី ៣១

(បិដក.៥៤.ទំព័រ.២២)

**រសេសុ គេធំ អករំ អលោលោ**
**អនញ្ញបោសី សបទានចារី**
**កុលេ កុលេ អប្បដិពទ្ធចិត្តោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលមិនធ្វើសេចក្ដីប្រាថ្នា ក្នុងរសទាំងឡាយ
ជាអ្នកមិនល្មោភ (ក្នុងអាហារ ) មិនចិញ្ចឹម
អ្នកដទៃ ជាអ្នកត្រាច់ទៅតាមច្រក មិនមានចិត្ត
ជាប់ចំពាក់ ក្នុងត្រកូលផ្សេង ៗ គប្បីត្រាច់ទៅ
តែម្នាក់ឯង កុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣២] អាចណគាថាទី ៣២

(បិដក.៥៤.ទំព័រ.២២)

**បហាយ បញ្ចាវរណានិ ចេតសោ**

**ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ**

**អនិស្សិតោ ឆេត្វា សិនេហទោសំ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលលះបង់ នូវនីវរណៈទាំង ៥ បន្ទោបង់

នូវឧបក្កិលេស នៃចិត្តទាំងអស់ចេញបាន

ជាអ្នកមិនអាស្រ័យ (ដោយតណ្ហា ) កាត់បង់នូវទោស

ដែលកើត អំពីសេចក្តីស្រឡាញ់ហើយ គប្បីត្រាច់ទៅ

តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣៣] វិបិដ្ឋិកត្វានគាថាទី ៣៣

(បិដក.៥៤.ទំព័រ.២៣)

**វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច**
**បុព្វេវ ច សោមនស្សទោមនស្សំ**
**លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលបានធ្វើនូវសុខទុក្ខនិងសោមនស្ស ទោមនស្ស ក្នុងកាលមុន ឲ្យនៅពីក្រោយខ្លួនហើយ បាននូវឧបេក្ខាសមថៈ (ក្នុងចតុត្ថជ្ឈាន )ដ៏បរិសុទ្ធហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣៨] អារទ្ធវីរិយគាថាទី ៣៨

(បិដក.៥៤.ទំព័រ.២៣)

**អារទ្ធវីរិយោ បរមត្ថបត្តិយា**
**អលីនចិត្តោ អកុសីតវុត្តិ**
**ទឡ្ហនិក្កមោ ថាមពលូបបន្នោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលមានសេចក្តីព្យាយាមប្រារព្ធ ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា អ្នកប្រព្រឹត្តមិនខ្ជិលច្រអូស មានសេចក្តីប្រឹងប្រែងដ៏មាំ ប្រកបដោយកម្លាំងប្រាជ្ញាហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣៥] បដិសល្លានគាថាទី ៣៥

(បិដក.៥៤.ទំព័រ.២៣)

**បដិសល្លានំ ឈានមរិញ្ចមានោ**
**ធម្មេសុ និច្ចំ អនុធម្មចារី**
**អាទីនវំ សម្មសិតា ភវេសុ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គល មិនលះបង់នូវឈាន ជាធម្មជាតស្ងប់ស្ងាត់ (ចាកសត្វនិងសង្ខារ ) ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណាឃើញទោស ក្នុងភពទាំងឡាយហើយ កប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣៦] តណ្ហក្ខយគាថាទី ៣៦

(បិដក.៥៤.ទំព័រ.២៤)

**តណ្ហក្ខយំ បត្ថយំ អប្បមត្តោ**

**អនេលមូគោ សុតវា សតីមា**

**សង្ខាតធម្មោ និយតោ បធានវា**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលកាលប្រាថ្នា នូវការអស់តណ្ហា ជា
អ្នកមិនប្រហែស មិនឆ្កួត មិនគ ជាអ្នកមានការ
ចេះដឹង មានស្មារតី មានជម្ពិចារណាហើយ
ជាបុគ្គលទៀង មានសេចក្តីព្យាយាម គប្បីត្រាច់ទៅ
តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

**[៣៧] អសន្តសន្តគាថាទី ៣៧**

(បិដក.៥៤.ទំព័រ.២៤)

**សីហោវ សទ្ទេសុ អសន្តសន្តោ**
**វាតោវ ជាលម្ហិ អសជ្ជមានោ**
**បទុមំវ តោយេន អលិម្បមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលមិនតក់ស្លុត (ក្នុងលក្ខណៈមានមិនទៀងជាដើម ) ដូចសីហៈ មិនតក់ស្លុតនឹងសំឡេងទាំងឡាយ មិនចាញជាប់ចំពាក់ (ក្នុងជមីទាំងឡាយ មានខន្ធជាដើម )ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនជាប់ (ដោយតណ្ហានិងលោភៈ ) ដូចឈូកមិនទទឹកដោយទឹក គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣៨] ទាឋពលិគាថាទី ៣៨

(បិដក.៥៤.ទំព័រ.២៤)

**សីហោ យថា ទាឋពលី បសយ្ហ**

**រាជា មិគានំ អភិភុយ្យចារី**

**សេវេថ បន្តានិ សេនាសនានិ**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលគប្បីអាស្រ័យ នូវសេនាសនៈ ដ៏ស្ងាត់

ដូចជាសីហៈ ជាស្តេចសត្វ មានកម្លាំងចង្កូម

ត្របាច់ ក្របសង្កត់ គំហែង នូវពួកម្រឹគ គប្បីត្រាច់ទៅ

តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៣៩] អប្បមញ្ញាគាថាទី ៣៩

(បិដក.៥៤.ទំព័រ.២៥)

**មេត្តំ ឧបេក្ខំ ករុណំ វិមុត្តំ**
**អាសេវមានោ មុទិតញ្ច កាលេ**
**សព្វេន លោកេន អវិរុជ្ឈមានោ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលកាលចម្រើនមេត្តាផង ឧបេក្ខាផង ករុណាផង
មុទិតាផង ដែលជាហេតុរួចស្រឡះ (ចាកកិលេស )
ក្នុងកាលគួរ មិនថ្នាំងថ្នាក់ ចំពោះសត្វលោកទាំងអស់
ហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៤០] ជីវិតសង្ខយគាថាទី ៤០

(បិដក.៥៤.ទំព័រ.២៥)

**រាគញ្ច ទោសញ្ច បហាយ មោហំ**
**សន្ទាលយិត្វាន សំយោជនានិ**
**អសន្តសំ ជីវិតសង្ខយម្ហិ**
**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលលះបង់រាគៈផង ទោសៈផង មោហៈផង ទម្លាយនូវសំយោជនៈទាំងឡាយ មិនតក់ស្លុតក្នុងការក្ស័យជីវិត គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

# ខគ្គវិសាណសូត្រ

## [៨១] ការណត្ថគាថាទី ៨១

(បិដក.៥៤.ទំព័រ.២៥)

**ភជន្តិ សេវន្តិ ច ការណត្ថា**

**និក្ការណា ទុល្លភា អជ្ជ មិត្តា**

**អត្តត្ថបញ្ញា អសុចី មនុស្សា**

**ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ពួកមនុស្សមានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផង ពួកមិត្តសម្លាញ់ទាំងឡាយ ដែលឥតហេតុ រកបានដោយក្រ ក្នុងថ្ងៃនេះ ពួកមនុស្ស (ច្រើនតែ) មានប្រាជ្ញាចំពោះប្រយោជន៍ របស់ខ្លួន ជាអ្នកប្រកបដោយអំពើមិនស្អាត បុគ្គលគប្បីត្រាច់ទៅ តែម្នាក់ឯងដូចកុយរមាស ។

# គម្ពីរជាឧបករណ៍ ក្នុងការរៀបរៀងសៀវភៅនេះឡើង

## ព្រះសុត្តន្តបិដកភាគ ៥៨

## អដ្ឋកថា បរមត្ថជោតិកា ភាគ ៥៨

(ក្រុមអ្នករៀបរៀងអដ្ឋកថា អរិវង្សយង់ សុជាត) ជាគោល

## អដ្ឋកថា បរមត្ថជោតិកា ភាគ ៥៨

(ក្រុមអ្នករៀបរៀងអដ្ឋកថា លោកគ្រូធម្មាចារ្យ ហាយ ចំរើន)

## វចនានុក្រមខ្មែរ

(សម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត)

## វត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង

**សូមអនុមោទនា.........!!!**

ថ្ងៃអាទិត្យ ៨រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣

**ភិក្ខុ មេត្តាធនោ មឿន សឺន**

# អ្នកមានឧបការៈក្នុងការចារធម្មទាន

| | | |
|---|---|---|
| សន្តចិត្តោ | វ៉េន | វដ្ឋា |
| ធរមុនិ | មី | នី |
| នេក្ខម្មានន្ទោ | អ៊ុង | ធិត្យា |
| អនុត្តរធម្មោ | នី | សុផានុត |
| ជវនប្បញ្ញោ | ឡុង | ជីវ៉ា |
| អត្ថកាមោ | មិន | វដ្ឋា |
| ឧបាសិកា | សុខសេង | មនោកញ្ញា |
| ឧបាសិកា | ហ៊ោ | ហៀលាក |

សៀវភៅដែលរៀបរៀងដោយ
ភិក្ខុមេត្តាធនោ មឿន សឺន

១.ភិក្ខុបាតិមោក្ខបាលី
២.សង្ឃកម្មសង្ខេប
៣.ទេវទូតសូត្រ
៤.ព្រះគាថាពន្ធ
៥.ពិធីបុណ្យបូជាព្រះសព ធម្មបាលោ ច្រាក់ យុន
៦.ខគ្គវិសាណសុត្តន្ត
ខគ្គវិសាណអដ្ឋកថា
៧.ខគ្គវិសាណសូត្រ



ការផ្សាយរបស់វត្តព្រៃគន្ធកុដិ
ភូមរំចេក ៣ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

# ធាបពលិគាថាទី ៣៨

សីហោ យថា ធាបពលី បសយ្ហ　　រាជា　មិគានំ　អភិភុយ្យចារី
សេវេថ បន្តានិ សេនាសនានិ　　ឯកោ ចរេ ខគ្គវិសាណកប្បោ ។

បុគ្គលគប្បីអាស្រ័យ　នូវសេនាសនៈ　ដ៏ស្ងាត់
ដូចជាសីហៈ ជាស្ដេចសត្វ មានកម្លាំងដង្កូមត្រាច់
គ្របសង្កត់　គាំហែង　នូវពួកម្រឹគ　គប្បីត្រាច់នៅ
តែម្នាក់ឯង ដូចកុយរមាស ។

(បិដក.៥៨.ទំព័រ.២៨)